# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២

## ការតាំងពិពណ៌ដើម្បីរំលឹកខួបទី៣០ឆ្នាំ នៃការចាប់ផ្តើមនៃ អាជ្ញាធរអន្តរកាលអង្គការសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់)

កាលពីយប់មិញនេះ ឯកឧត្តម ផាប្លូ កាង ឯកអគ្គរាជទូត អូស្ត្រាលីប្រចាំនៅកម្ពុជា បាន ចូលរួមជាមួយ ឯកឧត្តម ឧត្តមសេនីយ៍ឯក John Murray Sanderson AC អតីតមេបញ្ជាការកង កម្លាំងនៃអាជ្ញាធរអន្តរកាលអង្គការសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់) និង ឯកឧត្តម លី ធុច ទេស រដ្ឋមន្ត្រី និងជាអនុប្រធានទី១របស់អាជ្ញាធរមីន រួមទាំង ឥស្សរជនមួយចំនួន ក្នុងការបើកពិព័រណ៍រូប ថតរំលឹកខួបទី៣០ឆ្នាំ នៃអ៊ុនតាក់ នៅសណ្ឋាគារ Raffles Hotel Le Royal។

ពិពណ៌រូបថតនេះ រៀបចំដោយស្ថានទូតអូស្ត្រាលី ជាមួយ មជ្ឈមណ្ឌលសិក្សាបណ្តុះ បណ្តាលកសាងសន្តិភាព និងដោះស្រាយទំនាស់ និង វិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI) ដើម្បីរំលឹក ខួបលើកទី ៣០ឆ្នាំ នៃអ៊ុនតាក់ និងជាផ្នែកមួយនៃការអបអរខួបទី ៧០ឆ្នាំនៃទំនាក់ទំនងការទូតរវាង អូស្ត្រាលី និងកម្ពុជា។

អ៊ុនតាក់ ជាសម័យកាលប្រវត្តិសាស្ត្រមួយសម្រាប់ប្រទេសកម្ពុជា និងជាគំរូដ៏ល្អនៃកិច្ច សហប្រតិបត្តិការនយោបាយ និងសន្តិសុខអន្តរជាតិ ប្រកបដោយប្រសិទ្ធភាព។ វាត្រូវបានបង្កើត ឡើងដោយអង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៩២ ដើម្បីត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីស ការធ្វើមាតុភូមិនិវត្តន៍ប្រកបដោយសុវត្ថិភាព របស់ប្រជាជនកម្ពុជា ដែលបានផ្លាស់ទី លំនៅដោយសង្គ្រាមស៊ីវិល និងការបោះឆ្នោតជាតិឆ្នាំ ១៩៩៣ ។

ឯកឧត្តម ឯកអគ្គរាជទូត កាង បានមានប្រសាសន៍ថា "អូស្ត្រាលីមានមិត្តភាពដ៏យូរអង្វែង ជាមួយកម្ពុជា ព្រមទាំងជាប្រទេសមួយក្នុងចំណោមប្រទេសចំនួន១៩ ដែលបានចុះហត្ថលេខាលើ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសក្នុងខែតុលា ឆ្នាំ១៩៩១ ដែលបានត្រួសត្រាយផ្លូវដើម្បីការចាប់

ផ្ដើមរបស់អ៊ុនតាក់។ យើងទន្ទឹងរង់ចាំធ្វើការ រំលឹកខួបទី៣០ឆ្នាំរបស់អ៊ុនតាក់ ឆ្លុះបញ្ចាំងពីប្រវត្តិសាស្ត្ររួមរបស់យើង ព្រមទាំងអ្នកដែលបានបំពេញការងារដោយមិនខ្លាចនឿយហត់ ដើម្បីរៀបចំប្រទេសកម្ពុជាមកដល់សព្វថ្ងៃនេះ”។

ឧត្តមសេនីយ៍ឯក Sanderson របស់អូស្ត្រាលី បានបញ្ជាកងកម្លាំងពហុភាគីដ៏ធំរបស់ខ្លួនដែលមានកងវរសេនាតូចថ្មើរជើង និងអង្គភាពគាំទ្រ ចំនួន ១២ អ្នកសង្កេតការណ៍យោធា និងនគរបាលស៊ីវិល សរុបចំនួន ២២ ០០០ នាក់ មកពី ប្រហែល ៤០ ប្រទេសផ្សេងៗគ្នា។ បន្ថែមពីការផ្ដល់បញ្ជាការផ្នែកយោធា អូស្ត្រាលីក៏បានផ្ដល់បុគ្គលិកជាង ១ ២០០ នាក់ ដល់អ៊ុនតាក់ផងដែរ។

ស្ថានទូតក៏កំពុងរៀបចំកម្មវិធីពិភាក្សាប្រចាំសប្ដាហ៍នៅពេលថ្ងៃត្រង់ នៅតាមហ្វេសប៊ុករបស់ស្ថានទូត ពេញមួយខែក្នុងពេលតាំងពិព័រណ៍នេះផងដែរ ជាមួយនឹងបេសកកម្មការទូត សមភាគីរដ្ឋាភិបាលកម្ពុជា បណ្ឌិតសភា និងនិស្សិត។ ពិព័រណ៍រូបថតអ៊ុនតាក់ បើកជូនដល់សាធារណជនចាប់ពីម៉ោង ៧:០០ព្រឹក ដល់ម៉ោង ៩:០០យប់ ជារៀងរាល់ថ្ងៃ ចាប់ពីថ្ងៃទី២៩ ខែមេសា ដល់ថ្ងៃទី ២៨ ខែឧសភា។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au